ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** ជាតិ សាសនា ព្រះមហាក្សត្រ

លេខៈ ១៣៥ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការកែសម្រួលការរៀបចំ និងការប្រព្រឹត្តទៅ
# នៃគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ២៥ អនក្រ.បក ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ១៩៩៧ ស្តីពីការបង្កើតគណៈកម្មាធិ-ការសម្រាប់គោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់នៃការងាររបស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា ១.–**

អនុក្រឹត្យកែសម្រួលការរៀបចំ និងការប្រព្រឹត្តទៅរបស់ “**គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**” ដែលត្រូវបានបង្កើតឡើងដោយអនុក្រឹត្យលេខ ២៥ អនក្រ.បក ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ១៩៩៧។

សហការរៀបចំដោយអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល និងកម្មវិធីកំណែទម្រង់រដ្ឋបាល និងវិមជ្ឈការ (GIZ)-ចម្លងខ្លឹមសារទាំងស្រុងតាមច្បាប់ដើម

**មាត្រា ២.-**

“**គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** ” ហៅកាត់ “**គសហ** ” មានភារកិច្ចដឹកនាំរៀបចំ សម្របសម្រួលការអនុវត្ត និងតាមដានត្រួតពិនិត្យការអនុវត្តគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុរបស់រាជ-រដ្ឋាភិបាល មានជាអាទិ៍ ការងារពាក់ព័ន្ធនឹងកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ និងការអភិវឌ្ឍវិស័យឯកជន ព្រមទាំងមានភារកិច្ចសម្របសម្រួលរាល់កិច្ចសហប្រតិបត្តិការសម្រាប់ការអភិវឌ្ឍន៍ ឬសម្រាប់កំណែទម្រង់នៃវិស័យសេដ្ឋកិច្ច និងនៃវិស័យហិរញ្ញវត្ថុ របស់រាជរដ្ឋាភិបាលជាមួយដៃគូអភិវឌ្ឍន៍។

**មាត្រា ៣.-**

**គសហ** មានសមាសភាពដូចខាងក្រោម:

| | |
|---|---|
| ១- រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ប្រធាន |
| ២- ទេសាភិបាលធនាគារជាតិនៃកម្ពុជា | អនុប្រធាន |
| ៣- ប្រធានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ | អនុប្រធានប្រចាំការ |
| ៤- រដ្ឋមន្ត្រីក្រសួងផែនការ | សមាជិក |
| ៥- រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគររូបនីយកម្ម និងសំណង់ | សមាជិក |
| ៦- រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៧- រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ៨- រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | សមាជិក |
| ៩- រដ្ឋមន្ត្រីក្រសួងទេសចរណ៍ | សមាជិក |
| ១០- រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ១១- រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិក |
| ១២- រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម | សមាជិក |
| ១៣- រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ១៤- រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ១៥- អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |

**មាត្រា ៤.-**

**គសហ** ប្រើប្រាស់អគ្គលេខាធិការដ្ឋានក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាលេខាធិការដ្ឋាន។

**មាត្រា ៥.-**

ដើម្បីបំពេញបេសកកម្ម និងសម្រេចភារកិច្ចដូចមានចែងក្នុងមាត្រា២ ខាងលើ **គសហ** អាចបង្កើតគណៈកម្មាធិ-ការដឹកនាំការងារកែទម្រង់តាមវិស័យ រួមមានជាអាទិ៍ គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍវិស័យហិរញ្ញវត្ថុ គណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍវិស័យឯកជន ឬបង្កើតគណៈកម្មាធិការដឹកនាំការងារ ឬអនុគណៈកម្មាធិការ ឬក្រុមការងារបច្ចេកទេសផ្សេងទៀត

ទៅតាមការចាំបាច់ សម្រាប់ជួយដឹកនាំ រៀបចំ សម្របសម្រួលការអនុវត្ត និងតាមដានត្រួតពិនិត្យការអនុវត្តកម្មវិធីកំណែទម្រង់សេដ្ឋកិច្ច និងហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាលតាមវិស័យ ឬអនុវិស័យនីមួយៗ ព្រមទាំងសម្រាប់ជួយសម្របសម្រួលជាមួយដៃគូអភិវឌ្ឍន៍ដែលមានការពាក់ព័ន្ធ។

**មាត្រា ៦.–**

**គណៈកម្មាធិការដឹកនាំការងារតាមវិស័យ និង អនុគណៈកម្មាធិការ** ដែលមានលក្ខណៈអន្តរក្រសួង ត្រូវបង្កើតឡើងដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលតាមសំណើរបស់ **គសហ** ។

**មាត្រា ៧.–**

**គសហ** ព្រមទាំង **គណៈកម្មាធិការដឹកនាំការងារតាមវិស័យ អនុគណៈកម្មាធិការ** និង **ក្រុមការងារបច្ចេក-ទេស** មានសិទ្ធិអញ្ជើញតំណាងដៃគូអភិវឌ្ឍន៍ តំណាងវិស័យឯកជន និងតំណាងសង្គមស៊ីវិល ឱ្យចូលរួមក្នុងឋានៈជាសមាជិក ឬអ្នកសង្កេតការណ៍ ទៅតាមតម្រូវការចាំបាច់នៃការងារ។

**មាត្រា ៨.–**

**គសហ** មានសិទ្ធិអញ្ជើញប្រធានស្ថាប័ន ឬតំណាងនៃប្រធានស្ថាប័ន ព្រមទាំងមន្ត្រីបច្ចេកទេសនៃក្រសួង-ស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល មកចូលរួមប្រជុំ និងបំពេញការងារតាមការចាំបាច់។

**មាត្រា ៩.–**

– **គសហ** ធ្វើការតាមការអញ្ជើញរបស់ប្រធាន

– **គសហ** ប្រើប្រាស់ត្រារបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**មាត្រា ១០.–**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា ១១.–**

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទេសាភិបាលនៃធនាគារជាតិនៃកម្ពុជា ប្រធានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ រដ្ឋមន្ត្រីគ្រប់ក្រសួងពាក់ព័ន្ធ និងប្រធានស្ថាប័នពាក់ព័ន្ធ មានភារកិច្ចអនុវត្តអនុក្រឹត្យ នេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០០៧

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១១
- ឯកសារ–កាលប្បវត្តិ